# ការិយាល័យសហចៅក្រមស៊ើបអង្កេត
## បច្ចុប្បន្នភាពនៃសកម្មភាពរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត
## សំរាប់ខែ មីនា ឆ្នាំ ២០០៨

សហចៅក្រមស៊ើបអង្កេត សូមផ្តល់ជូននូវបច្ចុប្បន្នភាពជាទៀងទាត់នៃដំណើរការរីកចំរើននៃការស៊ើបសួរតាមតែអាចធ្វើបាន ដើម្បីជួយទៅដល់ការយល់ដឹងបន្ថែមពីកិច្ចការរបស់ការិយាល័យនេះ និងអំពីស្ថានភាពបច្ចុប្បន្ននៃដំណើរការនីតិវិធីរបស់ អ.វ.ត.ក។ ខាងក្រោមនេះគឺជាបច្ចុប្បន្នភាពក្នុងខែ មីនា ឆ្នាំ ២០០៨៖

១) ចាប់តាំងពីការចេញសេចក្តីប្រកាសព័ត៌មានចុងក្រោយរបស់ខ្លួនមក កិច្ចការរបស់សហចៅក្រមស៊ើបអង្កេត គឺផ្តោតទៅលើការបន្តការងារស៊ើបសួរលើសំណុំរឿងទាំងពីរ (០០១/១៨-០៧-២០០៧-ECCC-OCIJ និង ០០២/១៩-០៩-២០០៧-ECCC-OCIJ) ប៉ុន្តែជាពិសេស គឺផ្តោតទៅលើសំណុំរឿងទី១ ដែលទាក់ទិននឹង ស-២១ និងជនត្រូវចោទ **ឌុច** ដើម្បីសម្រួលដល់ការបិទការស៊ើបសួរលើសំណុំរឿងនេះឲ្យបានឆាប់រហ័ស។

តាមការពិត សហចៅក្រមស៊ើបអង្កេត មានបំណងជូនដំណឹងដល់ភាគីនានាថា ខ្លួនបានបញ្ចប់ការស៊ើបសួរលើសំណុំរឿងទី១ នៅដើមខែឧសភា ឆ្នាំ ២០០៨ (នេះគឺជាការជូនដំណឹងជាផ្លូវការ អនុលោមតាមវិធាន ៦៦ (១) នៃ វិធានផ្ទៃក្នុង)។ បន្ទាប់ពីការជូនដំណឹង សហចៅក្រមស៊ើបអង្កេត នឹងបន្តការងារទៀត ដើម្បីចេញដីកាដំណោះស្រាយផ្លូវការទាក់ទងទៅនឹងជនត្រូវចោទ **ឌុច** នាដើមខែកក្កដា ឆ្នាំ ២០០៨ ដែលដីកាដំណោះស្រាយនេះនឹងសម្រេចថា តើត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬយ៉ាងណា ហើយបើបញ្ជូនតើបញ្ជូនទៅជម្រះអំពីបទចោទអ្វី។ ទោះបីជាយ៉ាងណាក៏ដោយ នីតិវិធីនៅចន្លោះខែឧសភា និងរហូតដល់ពេលបញ្ចប់ចេញដីកាដំណោះស្រាយនាខែកក្កដា មិនអាស្រ័យតែលើសហចៅក្រមស៊ើបអង្កេតទេ ប៉ុន្តែវាអាស្រ័យផងដែរលើការអនុវត្តន៍សិទ្ធិទៅតាមនីតិវិធីរបស់ភាគីទាំងអស់។ ក្នុងបរិបទនេះ សហចៅក្រមស៊ើបអង្កេត បានចេញគំនិតផ្តួចផ្តើមមួយចំនួនដើម្បីធានាថា ភាគីទាំង

អស់យល់អំពីនីតិវិធី និងគម្រោងតារាងពេលវេលា ហើយបំពេញការងារក្នុងទិសដៅស្របគ្នាដើម្បីរក្សាបាននូវគោលបំណងនៃការបញ្ចប់សំណុំរឿងស៊ើបសួរនេះក្នុងខែកក្កដា ឆ្នាំ ២០០៨។

ផ្អែកលើមូលដ្ឋានទាំងនេះ សវនាការជំនុំជម្រះ **ឌុច** លើបទចោទប្រកាន់ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា សង្ឃឹមថាអាចនឹងចាប់ផ្តើមធ្វើនៅដើមត្រីមាសចុងក្រោយ ឆ្នាំ ២០០៨ ខាងមុខ។

ដូច្នេះហើយ នៅកំឡុងខែមីនា ឆ្នាំ ២០០៨ សហចៅក្រមស៊ើបអង្កេតបានរៀបចំផែនការដោយមធ្យ័តលើកិច្ចស៊ើបអង្កេតដែលនៅសេសសល់ ដែលតម្រូវឲ្យមាននៅក្នុងសំណុំរឿងទី ១ មុនពេលជូនដំណឹងដែលគ្រោងធ្វើនៅដើមខែឧសភា ឆ្នាំ ២០០៨ ហើយចំនុចដែលគួរឲ្យកត់សំគាល់គឺធ្វើការសួរចម្លើយមួយចំនួនទៀត បន្ទាប់ពីបានទទួលសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យមានកិច្ចស៊ើបសួរបន្ថែម។ នៅចុងខែមីនា ឆ្នាំ ២០០៨ **ឌុច** ត្រូវបានសួរចម្លើយបន្ថែមនៅ អ.វ.ត.ក ដោយសហចៅក្រម-ស៊ើបអង្កេតអស់រយៈពេល ៣ ថ្ងៃ។ ការសួរចម្លើយ **ឌុច** បន្ថែម ត្រូវបានគ្រោងទុកនាប៉ុន្មានសប្តាហ៍ខាងមុខនេះ។

២) ចំពោះជនត្រូវចោទ ៤ រូបទៀត ដែលនៅសល់ នៅក្នុងសំណុំរឿងទី ២ វិញ សហចៅក្រមស៊ើបអង្កេត បានដឹកនាំការពិនិត្យមើលឡើងវិញនៃយុទ្ធសាស្រ្តទាំងមូលអំពីរបៀបនៃការស៊ើបអង្កេត ក្រោយពេលចុះបេសកកម្មផ្សព្វផ្សាយព័ត៌មានមួយចំនួនមក។ មិនមានជនត្រូវចោទណាម្នាក់ក្នុងចំណោមជនត្រូវចោទទាំង ៤ នាក់នេះ យល់ព្រមអោយសហចៅក្រមស៊ើបអង្កេតសួរចម្លើយអំពីបញ្ហានានាដែលមាននៅក្នុងសំណុំរឿងទេ៖ កិច្ចស៊ើបសួរ កំពុងតែដំណើរការទៅយ៉ាងលឿន និងដោយឯករាជ្យពីជំហររបស់ជនត្រូវចោទ។

ជនជាប់ឃុំទាំង ៤ នាក់ នៅក្នុងសំណុំរឿងលេខ ២ ត្រូវបានក្រុមគ្រួសារមកសួរសុខទុក្ខ និងបានជួបមេធាវី ហើយទាំងអស់គ្នា (លើកលែងតែ **ខៀវ សំផន**) បានចូលរួមសវនាការ និង/ឬ សួរចម្លើយផ្សេងៗ នៅខែមីនានេះ។ សុខភាពរបស់ពួកគេ នៅថេរ។ **អៀង សារី** ត្រូវបាន នាំខ្លួនទៅកាន់មន្ទីរពេទ្យ កាល់ ម៉ែត នៅដើមខែមីនា ដើម្បីពិនិត្យសុខភាព។ ម្យ៉ាងទៀត បន្ទាប់ពី

សហចៅក្រម-ស៊ើបអង្កេត ចេញដីកាឲ្យមានការធ្វើកោសល្យវិច័យសុខភាពជាផ្លូវការ នៅដើមខែមីនា ទាំង **អៀង សារី** និង **នួន ជា** ត្រូវបានពិនិត្យសុខភាពនៅមន្ទីរពេទ្យ កាល់ ម៉ែត ដោយវេជ្ជបណ្ឌិតជាតិ និងអន្តរជាតិ ជំនាញខាងបេះដូង។

៣) ដោយគិតអំពីដើមបណ្តឹងរដ្ឋប្បវេណី និងផ្អែកតាមសំណើរបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា បានយល់ព្រមថា ខ្លួននឹងពង្រីកដែននៃការស៊ើបអង្កេតរបស់ខ្លួន ក្នុងសំណុំរឿងទី ២ ដើម្បីបញ្ចូលមន្ទីរសន្តិបាលដទៃទៀត ដែលអាចអនុញ្ញាតឲ្យមានដើមបណ្តឹងរដ្ឋប្បវេណី ៣ បន្ថែម ទៀត នៅក្នុងសំណុំរឿងទី ២។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដទៃទៀត កំពុងសិក្សាវិភាគដោយអង្គភាពជនរងគ្រោះ ហើយសង្ឃឹមថា នឹងរួចរាល់នាពេលអនាគតឆាប់ៗនេះ។

៤) នៅក្នុងខែមីនានេះដែរ បុគ្គលិករបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតមួយចំនួន បានចូលរួមក្នុងសិក្ខាសាលា និងសន្និសីទនានា នៅទីក្រុងភ្នំពេញ និងនៅតាមទីកន្លែងផ្សេងៗទៀត ក្នុងប្រទេសកម្ពុជា។ ការិយាល័យសហចៅក្រមស៊ើបអង្កេត មានសេចក្តីរីករាយក្នុងការធ្វើបទឧទ្ទេសន៍-នាម នៅក្នុងសន្និសីទដែលបានរៀបចំឡើងដោយក្លឹបអ្នកកាសែតកម្ពុជា កាលពីដើមខែមីនា ឆ្នាំ ២០០៨ និងដោយធ្វើការជាមួយផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក នឹងរៀបចំសន្និសីទមួយទៀត (គ្រោងធ្វើនៅដើមខែឧសភា ឆ្នាំ ២០០៨) ស្តីពីការផ្សព្វផ្សាយរបស់សារព័ត៌មានពីតុលាការបែបអន្តរជាតិ។ ការិយាល័យសហចៅក្រមស៊ើបអង្កេតជឿជាក់ថា ការធ្វើបែបនេះ នឹងបង្កើតបានជាវេទិកាមួយដ៏ប្រពៃ សំរាប់ការផ្លាស់ប្តូរទស្សនៈយោបល់ដែលចាំបាច់រវាងអ្នកសារព័ត៌មាន និងតំណាងរបស់ អ.វ.ត.ក។